DHCS
CALIFORNIA DEPARTMENT OF
HEALTH CARE SERVICES

Medi-Cal

# FAQ អំពីអន្តរកាលគម្រោងថែទាំសុខភាព Medi-Cal Managed Care

### តើហេតុអ្វីបានជាគម្រោងថែទាំសុខភាព Medi-Cal កំពុងផ្លាស់ប្តូរនៅតាមខោនធីមួយចំនួន?

រដ្ឋ California កំពុងផ្លាស់ប្តូរ Medi-Cal ដូច្នេះអ្នកអាចទទួលបានការថែទាំដែលអ្នកត្រូវការដើម្បីរស់នៅមានសុខភាពល្អ។

នៅក្នុងឆ្នាំ 2024 គម្រោងថែទាំសុខភាព Medi-Cal ត្រូវតែឆ្លើយតបឲ្យបានតាមច្បាប់ថ្មីសម្រាប់គុណភាព លទ្ធភាពទទួលបាន គណនេយ្យភាព និងតម្លាភាព។ ការឆ្លើយតបឲ្យបានតាមច្បាប់ថ្មីនេះនឹងធ្វើឲ្យប្រាកដថា សមាជិករបស់យើងទាំងអស់នៅទូទាំងរដ្ឋ មានលទ្ធភាពទទួលបានការថែទាំបានទាន់ពេលវេលា ប្រកបដោយគុណភាពខ្ពស់ពីគម្រោងសុខភាពទាំងអស់។

### តើការផ្លាស់ប្តូរចំពោះគម្រោងថែទាំសុខភាព Medi-Cal របស់ខ្ញុំប៉ះពាល់ដល់ធានារ៉ាប់រង Medi-Cal របស់ខ្ញុំឬទេ?

អត់ទេ។ បើទោះជាគម្រោងថែទាំសុខភាព Medi-Cal របស់អ្នកផ្លាស់ប្តូរក៏ដោយ ក៏ការធានារ៉ាប់រង និងអត្ថប្រយោជន៍ Medi-Cal ទាំងឡាយនឹងនៅដដែល។

### តើខ្ញុំដឹងថា គម្រោងថែទាំសុខភាព Medi-Cal របស់ខ្ញុំកំពុងផ្លាស់ប្តូរបានដោយរបៀបណា?

សូមស្វែងយល់ ថាតើគម្រោងថែទាំសុខភាព Medi-Cal របស់អ្នកនឹងមានការផ្លាស់ប្តូរឬអត់។

### តើខ្ញុំត្រូវធ្វើអ្វីខ្លះ ប្រសិនបើខ្ញុំរស់នៅក្នុងខោនធីមួយដែលកំពុងផ្លាស់ប្តូរគម្រោងថែទាំសុខភាព Medi-Cal?

#### គម្រោងថែទាំសុខភាព Medi-Cal កំពុងផ្លាស់ប្តូរ៖

ប្រសិនបើគម្រោងថែទាំសុខភាព Medi-Cal កំពុងផ្លាស់ប្តូរក្នុងខោនធីរបស់អ្នក នោះអ្នកប្រហែលជាត្រូវជ្រើសរើសគម្រោងថែទាំសុខភាព Medi-Cal ថ្មីមួយទៀត។

#### ការចុះឈ្មោះដោយស្វ័យប្រវត្តិ៖

ក្នុងខោនធីមួយចំនួន អ្នកនឹងត្រូវបានចុះឈ្មោះដោយស្វ័យប្រវត្តិក្នុងគម្រោងថែទាំសុខភាព Medi-Cal មួយដោយមិនចាំបាច់ជ្រើសរើសយកគម្រោងមួយឡើយ។

ព័ត៌មានលម្អិតសម្រាប់កុមារស្ថិតក្រោមការចិញ្ចឹមបីបាច់ថែទាំ និងសមាជិកជាយុវជនយុវនារី

### តើ Medi-Cal នឹងប្រាប់ខ្ញុំអំពីការផ្លាស់ប្តូរគម្រោងថែទាំសុខភាព Medi-Cal របស់ខ្ញុំដោយរបៀបណា?

ការផ្លាស់ប្តូរគម្រោងថែទាំសុខភាព គឺអាស្រ័យលើខោនធីដែលអ្នករស់នៅ។ សូមអានព័ត៌មានតាមខោនធីខាងក្រោមនេះ។

#### គម្រោងថែទាំសុខភាព Medi-Cal កំពុងផ្លាស់ប្តូរ៖

**ខោនធីមានជម្រើសគម្រោងថែទាំសុខភាព Medi-Cal (ការថែទាំក្រោមការគ្រប់គ្រងតាមភូមិសាស្ត្រ (Geographic Managed Care, GMC) គម្រោងពីរ និងខោនធីប្រចាំតំបន់)៖**

- Alpine
- Amador
- Calaveras
- El Dorado
- Fresno
- Inyo
- Kern
- Kings
- Los Angeles
- Madera
- Mono
- Riverside
- Sacramento
- San Bernardino
- San Diego
- San Francisco
- San Joaquin
- Santa Clara
- Stanislaus
- Tulare
- Tuolumne

**ប្រសិនបើអ្នករស់នៅក្នុងខោនធីមួយក្នុងចំណោមខោនធីដែលរាយខាងលើ ហើយគម្រោងថែទាំសុខភាព Medi-Cal របស់អ្នកកំពុងផ្លាស់ប្តូរ អ្នកអាចទទួលបានលិខិតមួយច្បាប់៖**

- **ខែតុលា ឆ្នាំ 2023៖** ប្រសិនបើសព្វថ្ងៃអ្នកនៅក្នុងគម្រោងថែទាំសុខភាព Medi-Cal មួយដែលនឹងចាកចេញពីខោនធីនៅបំណាច់ឆ្នាំ 2023 គម្រោងថែទាំសុខភាព Medi-Cal របស់អ្នកនឹងផ្ញើលិខិតតាមប្រៃសណីយ៍ទៅឲ្យអ្នក ដើម្បីប្រាប់អ្នកអំពីការផ្លាស់ប្តូរគម្រោងថែទាំសុខភាព Medi-Cal។
- **ខែវិច្ឆិកា និងធ្នូ ឆ្នាំ 2023៖** Medi-Cal នឹងផ្ញើលិខិតទៅឲ្យអ្នកថែមទៀតដោយមានព័ត៌មានបន្ថែមអំពី៖
  - ការចុះឈ្មោះគម្រោងថែទាំសុខភាព Medi-Cal ថ្មី
  - ជម្រើសថែមទៀតដែលអ្នកអាចមាន

**ប្រសិនបើអ្នកត្រូវជ្រើសរើសគម្រោងថែទាំសុខភាព Medi-Cal ថ្មីមួយ៖**

អ្នកនឹងទទួលបានកញ្ចប់ជម្រើសមួយ ដើម្បីជ្រើសរើសយកគម្រោងថែទាំសុខភាព Medi-Cal ថ្មីមួយក្នុងខោនធីរបស់អ្នក។ អ្នកត្រូវតែជ្រើសរើសយកគម្រោងថែទាំសុខភាព Medi-Cal ថ្មីមួយត្រឹមថ្ងៃទី **22 ខែធ្នូ ឆ្នាំ 2023**។ ប្រសិនបើអ្នកមិនជ្រើសរើស អ្នកនឹងត្រូវបានចុះឈ្មោះឲ្យដោយស្វ័យប្រវត្តិក្នុងគម្រោងថែទាំសុខភាព Medi-Cal ថ្មីមួយ ឬក្នុង Medi-Cal Fee-For-Service (ឧទាហរណ៍៖ កុមារស្ថិតក្រោមការចិញ្ចឹមបីបាច់ថែទាំ ឬសមាជិកជាយុវជនយុវនារី)។

  - **ខែធ្នូ ឆ្នាំ 2023៖** បន្ទាប់ពីអ្នកជ្រើសរើសគម្រោងថែទាំសុខភាព Medi-Cal ថ្មីមួយ ឬអ្នកត្រូវបានចុះឈ្មោះឲ្យដោយស្វ័យប្រវត្តិក្នុងគម្រោងថែទាំសុខភាព Medi-Cal ថ្មីមួយ Medi-Cal នឹងផ្ញើលិខិតមួយច្បាប់ឲ្យអ្នកតាមប្រៃសណីយ៍ដោយមានព័ត៌មានអំពីគម្រោងថែទាំសុខភាព Medi-Cal ថ្មីរបស់អ្នក។
  - **ខែមករា ឆ្នាំ 2024៖** គម្រោងថែទាំសុខភាព Medi-Cal ថ្មីរបស់អ្នកនឹងផ្ញើឲ្យអ្នកតាមប្រៃសណីយ៍នូវកញ្ចប់ស្វាគមន៍មួយ។

**បណ្តាខោនធីដែលមានគម្រោងតែមួយ ឬ ប្រព័ន្ធសុខភាពដែលរៀបចំតាមខោនធី (County-Organized Health System, COHS)៖**

- Alameda
- Butte
- Colusa
- Contra Costa
- Del Norte
- Glenn
- Humboldt
- Imperial
- Lake
- Lassen
- Marin
- Mariposa

- Mendocino
- Merced
- Modoc
- Monterey
- Napa
- Nevada
- Orange
- Placer
- Plumas
- San Benito
- San Luis Obispo
- San Mateo
- Santa Barbara
- Santa Cruz
- Shasta
- Sierra
- Siskiyou
- Solano
- Sonoma
- Sutter
- Tehama
- Trinity
- Ventura
- Yolo
- Yuba

ប្រសិនបើអ្នករស់នៅក្នុងខោនធីមួយដែលកំពុងផ្លាស់ប្តូរទៅគំរូគម្រោងតែមួយ ឬក្នុងខោនធីមួយដែលកំពុងផ្លាស់ប្តូរទៅគំរូប្រព័ន្ធសុខភាពដែលរៀបចំតាមខោនធី (COHS) អ្នកនឹងត្រូវបាន **ចុះឈ្មោះដោយស្វ័យប្រវត្តិ** ក្នុងគម្រោង COHS គម្រោងតែមួយ ឬ Kaiser Permanente។

- **ខែតុលា ឆ្នាំ 2023៖** ប្រសិនបើសព្វថ្ងៃអ្នកនៅក្នុងគម្រោងថែទាំសុខភាព Medi-Cal មួយដែលនឹងចាកចេញពីខោនធីនៅបំណាច់ឆ្នាំ 2023 គម្រោងថែទាំសុខភាព Medi-Cal របស់អ្នកនឹងផ្ញើលិខិតតាមប្រៃសណីយ៍ទៅឲ្យអ្នក ដើម្បីប្រាប់អ្នកអំពីការផ្លាស់ប្តូរគម្រោងថែទាំសុខភាព Medi-Cal។
- **ខែវិច្ឆិកា និងធ្នូ ឆ្នាំ 2023៖** Medi-Cal នឹងផ្ញើលិខិតទៅឲ្យអ្នកថែមទៀតដោយមានព័ត៌មានបន្ថែមអំពី៖
  - ការចុះឈ្មោះគម្រោងថែទាំសុខភាព Medi-Cal ថ្មី
  - ជម្រើសថែមទៀតដែលអ្នកអាចមាន
- **ខែធ្នូ ឆ្នាំ 2023៖** Medi-Cal នឹងផ្ញើលិខិតមួយច្បាប់ដោយមានព័ត៌មានអំពីការចុះឈ្មោះដោយស្វ័យប្រវត្តិរបស់អ្នកក្នុងគម្រោងថែទាំសុខភាព Medi-Cal ថ្មីមួយ ឬ Medi-Cal Fee-for-Service (FFS) (ឧទាហរណ៍៖ កុមារស្ថិតក្រោមការចិញ្ចឹមបីបាច់ថែទាំ ឬសមាជិកជាយុវជនយុវនារីក្នុងខោនធីដែលមានគម្រោងតែមួយ)។
- **ខែមករា ឆ្នាំ 2024៖** គម្រោងថែទាំសុខភាព Medi-Cal ថ្មីរបស់អ្នកនឹងផ្ញើកញ្ចប់ស្វាគមន៍មួយជូនទៅអ្នកតាមប្រៃសណីយ៍។

## តើខ្ញុំអាចបន្តប្រើប្រាស់សេវាពីវេជ្ជបណ្ឌិតរបស់ខ្ញុំបានទេ?

### ប្រសិនបើវេជ្ជបណ្ឌិតរបស់អ្នកស្ថិតក្នុងគម្រោងថែទាំសុខភាព Medi-Cal ថ្មីរបស់អ្នក៖

គម្រោងថែទាំសុខភាព Medi-Cal ថ្មីនានាក្នុងខោនធីរបស់អ្នក អាចដាក់បញ្ចូលវេជ្ជបណ្ឌិតរបស់អ្នកបាន។ ដើម្បីស្វែងយល់បន្ថែមអំពីជម្រើសគម្រោងថែទាំសុខភាព Medi-Cal និងវេជ្ជបណ្ឌិតរបស់អ្នក ដែលសហការជាមួយបណ្ដាគម្រោងថែទាំសុខភាព Medi-Cal សូមចូលទៅមើលនៅគេហទំព័រ៖ **www.healthcareoptions.dhcs.ca.gov**។

### ប្រសិនបើវេជ្ជបណ្ឌិតរបស់អ្នកមិនស្ថិតក្នុងគម្រោងថែទាំសុខភាព Medi-Cal ថ្មីរបស់អ្នក៖

- ប្រសិនបើអ្នកបានទៅជួបវេជ្ជបណ្ឌិត Medi-Cal ម្នាក់ក្នុងរយៈពេល **12 ខែ** កន្លងមកនេះ ដែលមិនស្ថិតនៅក្នុងគម្រោងថែទាំសុខភាព Medi-Cal ថ្មីរបស់អ្នក នោះអ្នកប្រហែលជាអាចបន្តប្រើប្រាស់សេវាពីវេជ្ជបណ្ឌិតរបស់អ្នកប្រសិនបើអ្នកស្នើសុំគម្រោងថែទាំសុខភាព Medi-Cal ថ្មីរបស់អ្នកសម្រាប់ ការថែទាំបន្ត (continuity of care)។

- ការថែទាំបន្ត មានន័យថា អ្នកអាចរក្សាអ្នកផ្តល់សេវា Medi-Cal សម្រាប់រយៈពេលដល់ទៅ 12 ខែ ក្រោយពេលអ្នកចូលរួមក្នុងគម្រោងថែទាំសុខភាព Medi-Cal ថ្មី។ នេះរាប់បញ្ចូលទាំង វេជ្ជបណ្ឌិតថែទាំបឋម (primary care doctor, PCP) របស់អ្នក គ្រូពេទ្យឯកទេស អ្នកព្យាបាលខាងរាងកាយ និងមុខរបរ និងជាច្រើនទៀត។
- វេជ្ជបណ្ឌិតរបស់អ្នកអាចយល់ព្រមធ្វើការជាមួយគម្រោងថែទាំសុខភាព Medi Cal ថ្មីរបស់អ្នក។ នេះអាចមានរយៈពេលរហូតដល់ 12 ខែ ឬច្រើនជាងនេះនៅក្នុងករណីមួយខ្លះ។
- ការថែទាំបន្តមានសារៈសំខាន់ចំពោះសុខភាព និងសុខុមាលភាពរបស់អ្នក។ (សេចក្តីជូនដំណឹងស្តីពីព័ត៌មានបន្ថែម)
- ប្រសិនបើអ្នកចង់បានការថែទាំបន្ត សូមហៅទូរសព្ទទៅកាន់សេវាបម្រើសមាជិករបស់គម្រោងថែទាំសុខភាព Medi-Cal ថ្មីរបស់អ្នក នៅពេលអ្នកចូលរួមគម្រោងថែទាំសុខភាព Medi-Cal ថ្មី។
- ដើម្បីស្វែងយល់បន្ថែមអំពីជម្រើសគម្រោងថែទាំសុខភាព Medi-Cal និងវេជ្ជបណ្ឌិតរបស់អ្នក ដែលសហការជាមួយបណ្តាគម្រោងថែទាំសុខភាព Medi-Cal សូមចូលទៅមើលនៅគេហទំព័រ៖ **www.healthcareoptions.dhcs.ca.gov**។

### ប្រសិនបើអ្នកត្រូវការវេជ្ជបណ្ឌិតថ្មីម្នាក់៖

ប្រសិនបើវេជ្ជបណ្ឌិតរបស់អ្នកមិនយល់ព្រមធ្វើការជាមួយគម្រោងថែទាំសុខភាព Medi-Cal ថ្មីរបស់អ្នក នោះគម្រោងថែទាំសុខភាព Medi-Cal ថ្មីរបស់អ្នកនឹងជួយស្វែងរកវេជ្ជបណ្ឌិតថ្មី។

### ប្រសិនបើគម្រោងថែទាំសុខភាព Medi-Cal របស់ខ្ញុំកំពុងផ្លាស់ប្តូរ តើខ្ញុំអាចស្ថិតនៅក្នុងគម្រោងការគ្រប់គ្រងលើការថែទាំដែលប្រសើរ (Enhanced Care Management, ECM) និងជំនួយសហគមន៍ ដដែលបានទេ នៅចន្លោះខែតុលា ឆ្នាំ 2023 និងថ្ងៃទី 31 ខែធ្នូ ឆ្នាំ 2023?

បាន។ សមាជិកដែលស្ថិតក្នុងគម្រោងថែទាំសុខភាព Medi-Cal មួយនៅពេលឥឡូវនេះ នៅតែអាចត្រូវបានគេចុះឈ្មោះក្នុងគម្រោង ECM និងជំនួយសហគមន៍ក្នុងគម្រោងថែទាំសុខភាព Medi-Cal នោះបាន រហូតដល់ថ្ងៃទី 31 ខែធ្នូ ឆ្នាំ 2023។

### ប្រសិនបើខ្ញុំជាសមាជិកថ្មីនៅក្នុង Medi-Cal តើគេអាចចុះឈ្មោះខ្ញុំក្នុងការគ្រប់គ្រងលើការថែទាំដែលប្រសើរ (ECM) និងជំនួយសហគមន៍ បានទេ នៅចន្លោះខែតុលា 2023 និងថ្ងៃទី 31 ខែធ្នូឆ្នាំ 2023?

វាអាស្រ័យ។ មានតែបណ្តាគម្រោងសុខភាព Medi-Cal ប៉ុណ្ណោះដែលផ្តល់ ECM និងជំនួយសហគមន៍។ គម្រោងទាំងនោះមិនមាននៅក្នុង Medi-Cal Fee-For-Service (FFS) ទេ។ ប្រសិនបើអ្នកចូលរួមក្នុងគម្រោងថែទាំសុខភាព Medi-Cal មួយនៅក្នុងខោនធីរបស់អ្នកឥឡូវនេះ អ្នកនឹងត្រូវបានចុះឈ្មោះនៅថ្ងៃទីមួយនៃខែបន្ទាប់។ អ្នកអាចប្រើគម្រោង ECM និងជំនួយសហគមន៍ ក្រោយកាលបរិច្ឆេទចុះឈ្មោះរបស់អ្នក។

ប្រសិនបើអ្នកចូលរួមក្នុងគម្រោងថែទាំសុខភាព Medi-Cal មួយ ដែលថ្មីក្នុងខោនធីរបស់អ្នក ចាប់ផ្តើមពីថ្ងៃទី 1 ខែមករា ឆ្នាំ 2024 អ្នកនឹងស្ថិតនៅក្នុងគម្រោង Medi-Cal FFS ដដែលរហូតដល់គម្រោងថែទាំសុខភាព Medi-Cal ថ្មីរបស់អ្នកចាប់ផ្តើមនៅថ្ងៃទី 1 ខែមករា ឆ្នាំ 2024។ អ្នកនឹងមិនទទួលបាន ECM និងជំនួយសហគមន៍ទេ រហូតទាល់តែក្រោយកាលបរិច្ឆេទដែលគម្រោងថែទាំសុខភាព Medi-Cal ថ្មីរបស់អ្នកចាប់ផ្តើម។

ដើម្បីស្វែងយល់បន្ថែមអំពីបណ្តាគម្រោងថែទាំសុខភាព Medi-Cal ដែលមានស្រាប់ និងគម្រោងថែទាំសុខភាព Medi-Cal ថ្មីៗ ដែលចាប់ផ្តើមនៅថ្ងៃទី 1 ខែមករា ឆ្នាំ 2024 សូមអាន បញ្ជីគម្រោងថែទាំសុខភាព Medi-Cal តាមខោនធី។

## តើមានអ្វីខ្លះនឹងត្រូវផ្លាស់ប្តូរសម្រាប់កុមារស្ថិតក្រោមការចិញ្ចឹមបីបាច់ថែទាំ និងយុវជនយុវនារី?

### ប្រសិនបើអ្នករស់នៅក្នុងខោនធីមួយក្នុងចំណោមខោនធីទាំងនេះ៖

- Butte
- Colusa
- Glenn
- Mariposa
- Nevada
- Placer
- Plumas
- San Benito
- Sierra
- Sutter
- Tehama
- Yuba

  - ខោនធីរបស់អ្នកកំពុងផ្លាស់ប្តូរទៅគំរូប្រព័ន្ធសុខភាពដែលរៀបចំតាមខោនធី (COHS)។
  - អ្នកត្រូវតែចុះឈ្មោះក្នុងគម្រោងថែទាំសុខភាព Medi-Cal ក្នុងខោនធីរបស់អ្នក។
  - អ្នកនឹងទទួលបានលិខិតផ្សេងៗពី Medi-Cal ក្នុងខែវិច្ឆិកា និងធ្នូ ដើម្បីជម្រាបជូនអ្នកអំពីការផ្លាស់ប្តូរនេះ។
  - ក្នុងខែមករា អ្នកនឹងទទួលបានកញ្ចប់ស្វាគមន៍មួយពីគម្រោងថែទាំសុខភាព Medi-Cal ថ្មីរបស់អ្នក។
  - កញ្ចប់ស្វាគមន៍នេះសំខាន់ក្នុងការជ្រើសរើសអ្នកផ្តល់សេវាថែទាំបឋមម្នាក់ (PCP)។ គម្រោងថែទាំសុខភាព Medi-Cal ថ្មីរបស់អ្នកអាចជួយអ្នកជ្រើសរើសយកម្នាក់មួយបាន។
  - ប្រសិនបើអ្នកមាន PCP ម្នាក់ឥឡូវនេះ អ្នកគួរតែហៅទូរសព្ទទៅកាន់គម្រោងថែទាំសុខភាព Medi-Cal ថ្មីរបស់អ្នក ដើម្បីធ្វើឲ្យប្រាកដថា វេជ្ជបណ្ឌិតរបស់អ្នកធ្វើការជាមួយនឹងគម្រោងថែទាំសុខភាព Medi-Cal ថ្មីរបស់អ្នក។

### ប្រសិនបើអ្នករស់នៅក្នុងខោនធីមួយក្នុងចំណោមខោនធីទាំងនេះ៖

- Alpine
- El Dorado

  - ខោនធីរបស់អ្នកកំពុងផ្លាស់ប្តូរទៅកាន់គំរូគម្រោងពីរ។
  - ប្រសិនបើអ្នកស្ថិតក្នុងគម្រោង Fee-For-Service (FFS) Medi-Cal ឥឡូវនេះ អ្នកនឹង **មិន** ទទួលបានលិខិតក្នុងចុងឆ្នាំ 2023 ទេ។ វានៅតែជាការស្ម័គ្រចិត្តសម្រាប់អ្នកក្នុងការចូលក្នុងគម្រោងថែទាំសុខភាព Medi-Cal។
  - ប្រសិនបើអ្នកជាសមាជិកស្ម័គ្រចិត្តក្នុងគម្រោងថែទាំសុខភាព Medi-Cal ក្នុងពេលឥឡូវនេះ ដែលនឹងមិនស្ថិតក្នុងខោនធីនេះ ចាប់ពីថ្ងៃទី 1 ខែមករា ឆ្នាំ 2024 នោះអ្នកនឹងទទួលបានលិខិតមួយច្បាប់ពីគម្រោងថែទាំសុខភាព Medi-Cal នោះ ក្នុងខែតុលា។ លិខិតនោះនឹងប្រាប់អ្នកថា ពួកគេនឹងមិននៅក្នុងគម្រោងសុខភាព Medi-Cal របស់អ្នក ចាប់ពីខែមករា។
  - អ្នកក៏នឹងទទួលបានលិខិតផ្សេងៗពី Medi-Cal ក្នុងខែវិច្ឆិកា និងធ្នូ ដើម្បីជម្រាបជូនអ្នកអំពីការផ្លាស់ប្តូរនេះ។
  - អ្នកនឹងទទួលបានកញ្ចប់ចុះឈ្មោះដោយស្ម័គ្រចិត្តមួយពី Medi-Cal ដើម្បីជ្រើសរើសយកគម្រោងថែទាំសុខភាព Medi-Cal មួយក្នុងខោនធីរបស់អ្នក ប្រសិនបើអ្នកនៅក្នុងគម្រោងថែទាំសុខភាព Medi-Cal មួយ។

- ប្រសិនបើអ្នកមិនជ្រើសរើសយកគម្រោងថែទាំសុខភាព Medi-Cal មួយទេ អ្នកនឹងចូលក្នុងគម្រោង FFS Medi-Cal ចាប់ពីថ្ងៃទី 1 ខែមករា ឆ្នាំ 2024។

### ប្រសិនបើអ្នករស់នៅក្នុងខោនធីមួយក្នុងចំណោមខោនធីទាំងនេះ៖

- Alameda
- Contra Costa
- Imperial
  - ខោនធីរបស់អ្នកកំពុងផ្លាស់ប្តូរទៅគំរូគម្រោងតែមួយ។
  - ប្រសិនបើអ្នកស្ថិតក្នុងគម្រោង Fee-For-Service (FFS) Medi-Cal ឥឡូវនេះ អ្នកនឹង **មិន** ទទួលបានលិខិតក្នុងចុងឆ្នាំ 2023 ទេ។ វានៅតែជាការស្ម័គ្រចិត្តសម្រាប់អ្នកក្នុងការចូលក្នុងគម្រោងថែទាំសុខភាព Medi-Cal។
  - ប្រសិនបើអ្នកជាសមាជិកស្ម័គ្រចិត្តក្នុងគម្រោងថែទាំសុខភាព Medi-Cal មួយក្នុងពេលឥឡូវនេះ ដែលនឹងមិនមានក្នុងខោនធីនេះ នៅថ្ងៃទី 1 ខែមករា ឆ្នាំ 2024 នោះអ្នកនឹងទទួលបានលិខិតមួយច្បាប់ពីគម្រោងថែទាំសុខភាព Medi-Cal នោះក្នុងខែតុលា។ លិខិតនោះនឹងប្រាប់អ្នកថា ពួកគេនឹងមិននៅក្នុងគម្រោងសុខភាព Medi-Cal របស់អ្នក ចាប់ពីខែមករា។
  - អ្នកក៏នឹងទទួលបានលិខិតផ្សេងៗពី Medi-Cal ក្នុងខែវិច្ឆិកា និងធ្នូ ដើម្បីជម្រាបជូនអ្នកអំពីការផ្លាស់ប្តូរនេះ។
  - ដើម្បីចូលរួមក្នុងគម្រោងថែទាំសុខភាព Medi-Cal ថ្មីមួយ សូមហៅទូរសព្ទទៅ Medi-Cal Health Care Options (HCO) ចាប់ពីថ្ងៃចន្ទ – ថ្ងៃសុក្រ ពីម៉ោង 8 ព្រឹក ដល់ម៉ោង 6 ល្ងាច តាមលេខ 1-800-430-5005 (TTY: 1-800-430-7077)។ ឬទៅកាន់គេហទំព័រ **www.healthcareoptions.dhcs.ca.gov**។
  - ប្រសិនបើអ្នកមិនជ្រើសរើសយកគម្រោងថែទាំសុខភាព Medi-Cal ថ្មីមួយទេ អ្នកនឹងស្ថិតនៅក្នុងគម្រោង FFS Medi-Cal ដដែល។ សមាជិកជាកុមារដែលស្ថិតក្រោមការចិញ្ចឹមបីបាច់ថែទាំ និងយុវជនយុវនារីនៅក្នុងខោនធីដែលមានគម្រោងតែមួយ មិនចាំបាច់ចុះឈ្មោះក្នុងគម្រោងថែទាំសុខភាព Medi-Cal មួយរហូតដល់ឆ្នាំ 2025។

### តើ Medicare របស់ខ្ញុំផ្លាស់ប្តូរទេ ប្រសិនបើខ្ញុំមានទាំង Medi-Cal ទាំង Medicare (មានសិទ្ធិទទួលបានទាំងពីរ)?

អត់ទេ អត្ថប្រយោជន៍ និងអ្នកផ្តល់សេវាកម្មវិធី Medicare របស់អ្នក នឹង **មិន** ផ្លាស់ប្តូរទេ នៅពេលគម្រោងថែទាំសុខភាព Medi-Cal របស់អ្នកផ្លាស់ប្តូរ។

អ្នកផ្តល់សេវារបស់កម្មវិធី Medicare របស់អ្នក៖

- មិនចាំបាច់ស្ថិតនៅក្នុងបណ្តាញគម្រោងថែទាំសុខភាព Medi-Cal របស់អ្នក ដើម្បីបន្តដំណើរការផ្តល់ជូនការថែទាំសុខភាពដល់អ្នក ប៉ុន្តែពួកគេត្រូវឲ្យគេចុះឈ្មោះជាអ្នកផ្តល់សេវារបស់ Medi-Cal។
- មិនអាចគិតថ្លៃពីអ្នកលើការបង់ប្រាក់រួម ការធានារ៉ាប់រងរួម និងចំណាយបង់មុនបានទេ ប្រសិនបើអ្នកស្ថិតនៅក្នុងកម្មវិធី Medi-Cal។

- អាចដាក់ស្នើវិក្កយបត្រលើការចំណាយបង់ប្រាក់រួម ការធានារ៉ាប់រងរួម និងចំណាយបង់មុនទៅកាន់គម្រោងថែទាំសុខភាព Medi-Cal របស់អ្នក បើទោះបីជាពួកគេមិនស្ថិតនៅក្នុងបណ្តាញកម្មវិធី Medi-Cal ក៏ដោយ។

ប្រសិនបើអ្នកមានសំណួរអំពី Medicare ឬគម្រោង Medicare Advantage សូមហៅទូរសព្ទមកលេខ 1-800-MEDICARE ឬលេខដែលមាននៅលើបណ្ណសមាជិកគម្រោង Medicare Advantage របស់អ្នក។ សូមស្វែងយល់បន្ថែម។

### តើគម្រោងសុខភាព PACE និង SCAN ផ្លាស់ប្តូរទេ ប្រសិនបើគម្រោងថែទាំសុខភាព Medi-Cal របស់ខ្ញុំផ្លាស់ប្តូរ?

អត់ទេ គម្រោងទាំងនេះនឹងមិនផ្លាស់ប្តូរទេ៖

Program of All-Inclusive Care for the Elderly (PACE)

Senior Care Action Network (SCAN)

អ្នកអាចស្វែងយល់បន្ថែមតាមរយៈ៖

របៀបចុះឈ្មោះនៅក្នុងគម្រោងថែទាំសុខភាព PACE ឬ SCAN

### តើមានការការពារអ្វីខ្លះសម្រាប់សមាជិកដែលមានដើមកំណើត American Indian និង Alaska Native អំឡុងពេលមានការផ្លាស់ប្តូរនេះ?

#### ប្រសិនបើអ្នកមានអ្នកផ្តល់សេវាថែទាំសុខភាពដែលមានដើមកំណើត Indian៖

សមាជិកដែលមានដើមកំណើត American Indian/Alaska Native (AI/AN) អាចទទួលបានសេវាថែទាំសុខភាពពីអ្នកផ្តល់សេវាណាមួយរបស់គម្រោង ថែទាំសុខភាពឥណ្ឌា (Indian Health Care) នៅពេលណាក៏បាន។

សម្រាប់ជំនួយ ទាក់ទងមក៖

- គម្រោងសុខភាព Medi-Cal របស់សមាជិក **ឬ**
- Medi-Cal Ombudsman
  - **លេខទូរសព្ទ៖** 1-888-452-8609 (ហៅទូរសព្ទដោយឥតគិតថ្លៃ)
  - **TTY:** 711 សម្រាប់ California State Relay
  - **អ៊ីមែល៖** MMCDOmbudsmanOffice@dhcs.ca.gov

#### ប្រសិនបើអ្នកមានអ្នកផ្តល់សេវាថែទាំសុខភាព មិនមែនជាឥណ្ឌា (Non-Indian)៖

សមាជិក AI/AN ដែលទទួលបានការថែទាំពីអ្នកផ្តល់សេវាម្នាក់ដែលមិនមែនជា Indian Health Care Provider (IHCP) អាចរក្សាទុកអ្នកផ្តល់សេវាដដែលបាន ប្រសិនបើពួកគេទទួលបាន ការថែទាំបន្ត។

ទាក់ទងមកគម្រោងថែទាំសុខភាព Medi-Cal របស់អ្នក ប្រសិនបើអ្នកត្រូវការជំនួយខាង ការថែទាំបន្ត។

#### ការមិនចូលរួមក្នុងការគ្រប់គ្រងការថែទាំ៖

- សមាជិក AI/AN អាចមិនចូលរួមក្នុងការគ្រប់គ្រងការថែទាំនៅតាមខោនធីមួយចំនួន។
- សម្រាប់ខោនធីដែលសមាជិកមិនអាចមិនចូលរួមបាន សមាជិកនោះនៅតែមានសិទ្ធិទទួលបានការពិនិត្យពី IHCP បើទោះជាពួកគេមិននៅជាមួយគម្រោងសុខភាព Medi-Cal ក៏ដោយ។

- សូមស្វែងយល់បន្ថែម៖
  - សូមអាន សេចក្ដីជូនដំណឹងស្ដីពីព័ត៌មានបន្ថែម
  - ទាក់ទងមក Health Care Options
    - **លេខទូរសព្ទ៖** 1-800-430-5005
    - **គេហទំព័រ៖ www.healthcareoptions.dhcs.ca.gov**

**តើខ្ញុំត្រូវធ្វើអ្វីខ្លះ ប្រសិនបើគេធ្វើស្រោមសំបុត្រពណ៌លឿងតាមប្រៃសណីយ៍មក ដោយមានបែបបទសុំបន្ត Medi-Cal បន្ថែមពីលើលិខិតដែលបង្ហាញថា គម្រោងថែទាំសុខភាព Medi-Cal របស់ខ្ញុំកំពុងផ្លាស់ប្ដូរ?**
បំពេញបែបបទសុំបន្ត Medi-Cal របស់អ្នកជាមុនសិន។ ប្រសិនបើអ្នកមិនបំពេញបែបបទសុំបន្តរបស់អ្នកត្រឹមកាលបរិច្ឆេទកំណត់ ដែលព្រីនចេញលើបែបបទសុំបន្តនោះ អ្នកអាចបាត់បង់ធានារ៉ាប់រង Medi-Cal របស់អ្នក។ សូមមើលគេហទំព័រអំពី "រក្សា Medi-Cal របស់អ្នក" សម្រាប់ព័ត៌មានអំពីរបៀបបំពេញបែបបទសុំបន្ត Medi-Cal របស់អ្នក។

ក្រោយពីបំពេញបែបបទសុំបន្ត Medi-Cal របស់អ្នករួចហើយ សូមពិនិត្យមើលលិខិតពី Medi-Cal អំពីការផ្លាស់ប្ដូររបស់អ្នកក្នុងគម្រោងថែទាំសុខភាព Medi-Cal។ ដូចបានរៀបរាប់នៅក្នុង FAQ ខាងលើ (មើល "តើ Medi-Cal នឹងប្រាប់ខ្ញុំអំពីការផ្លាស់ប្ដូរចំពោះគម្រោងថែទាំសុខភាព Medi-Cal របស់ខ្ញុំដោយរបៀបណា?") សមាជិក Medi-Cal នឹងត្រូវបានចុះឈ្មោះដោយស្វ័យប្រវត្តិក្នុងគម្រោងថែទាំសុខភាព Medi-Cal ថ្មីមួយ ឬមានជម្រើសសកម្មមួយនៃគម្រោងថែទាំសុខភាព Medi-Cal ថ្មីមួយ អាស្រ័យលើខោនធីដែលអ្នករស់នៅ។ ប្រសិនបើអ្នករក្សាធានារ៉ាប់រង Medi-Cal របស់អ្នក នោះអ្នកនឹងត្រូវបានចុះឈ្មោះនៅក្នុងគម្រោងថែទាំសុខភាព Medi-Cal ថ្មីមួយ បើទោះបីជាអ្នកមិនជ្រើសរើសយ៉ាងសកម្មនូវគម្រោងមួយតាមកាលបរិច្ឆេទដែលចុះនៅលើកញ្ចប់ *My Medi-Cal Choice* សម្រាប់ការចុះឈ្មោះ ថ្ងៃទី 1 ខែមករា ឆ្នាំ 2024 ក៏ដោយ។

Medi-Cal នឹងផ្ញើលិខិតដែលទាក់ទងនឹងការផ្លាស់ប្ដូរក្នុងបណ្ដាគម្រោងថែទាំសុខភាព Medi-Cal ទៅឲ្យសមាជិកម្នាក់ៗ ដែលត្រូវបានចុះឈ្មោះ ហើយមានសិទ្ធិទទួលបាន Medi-Cal ត្រឹមពេលដែលផ្ញើលិខិត (ក្នុងខែវិច្ឆិកា និងធ្នូ ឆ្នាំ 2023)។ ប្រសិនបើអ្នកបាត់បង់ការធានារ៉ាប់រង Medi-Cal របស់អ្នក ហើយធានារ៉ាប់រងនោះមិនត្រូវបានយកមកបន្តវិញ មុនថ្ងៃទី 1 ខែមករា ឆ្នាំ 2024 អ្នកមិនចាំបាច់ធ្វើអ្វីចំពោះការជ្រើសរើសគម្រោងថែទាំសុខភាព Medi-Cal មួយនោះ។ សូមមើលគេហទំព័រអំពី "ការចាប់ផ្ដើមធានារ៉ាប់រងរបស់អ្នកឡើងវិញ (Restart Your Coverage)" សម្រាប់ព័ត៌មានអំពីជម្រើសធានារ៉ាប់រងរបស់អ្នក ប្រសិនបើអ្នកទទួលបានសេចក្ដីជូនដំណឹងពី Medi-Cal ថា ធានារ៉ាប់រងរបស់អ្នកបានបញ្ចប់។

**តើខ្ញុំអាចស្វែងយល់បន្ថែមទៀតអំពីគម្រោងថែទាំសុខភាព Medi-Cal នៅឯណា?**
ស្វែងយល់បន្ថែមអំពី ជម្រើស និងអត្ថប្រយោជន៍របស់គម្រោងគ្រប់គ្រងការថែទាំសុខភាព Medi-Cal។

**តើខ្ញុំអាចទទួលបានជំនួយ និងព័ត៌មានបន្ថែមនៅឯណា?**
ចូលទៅមើលគេហទំព័រទំនាក់ទំនងមកយើងខ្ញុំរបស់ MCP។